ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
លេខ....៥៣១.......កកន/សរ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់ម៉ោងធ្វើការសម្រាប់មន្ត្រីរាជការ
# នៅថ្នាក់ជាតិទាំងអស់នៃក្រសួងកិច្ចការនារី

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញ អនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា
- យោង កិច្ចប្រជុំថ្ងៃទី០៩ និងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងកិច្ចការនារី

## សម្រេច

**ប្រការ១.**

ត្រូវបានកំណត់ម៉ោងធ្វើការងារសម្រាប់មន្ត្រីរាជការនៅថ្នាក់ជាតិទាំងអស់ នៃក្រសួងកិច្ចការនារី ៨(ប្រាំបី)ម៉ោងក្នុងមួយថ្ងៃ និង៥(ប្រាំ)ថ្ងៃក្នុងមួយសប្តាហ៍ (ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ) ចាប់ពីម៉ោង ៨:៣០នាទីព្រឹក ដល់ម៉ោង ១៦:៣០នាទីរសៀល និងទុករយៈពេល ១(មួយ)ម៉ោង សម្រាប់ទទួលទានអាហារថ្ងៃត្រង់។

ផ្លូវត្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩
ទូរសារ : ០២៣ ៨៨០ ៧៣៧

**ប្រការ២.-**

ត្រូវបានអនុញ្ញាតឲ្យចាប់ផ្តើមនិងចេញពីធ្វើការមុននិង/ឬក្រោយម៉ោងកំណត់នៃការងារក្នុង ១(មួយ)ថ្ងៃមិនឲ្យលើសពី១(មួយ)ម៉ោង ចំពោះមន្ត្រីរាជការនៅថ្នាក់ជាតិទាំងអស់ដែលមានស្ថាន-ភាព ដូចខាងក្រោម ៖

-មន្ត្រីរាជការដែលមានជនចាស់ជរា ឬជនដែលមានស្មារតីវិបល្លាស ឬជនពិការអចិន្ត្រៃយ៍ក្នុងបន្ទុក

-មន្ត្រីរាជការដែលមានផ្ទៃពោះ

-មន្ត្រីរាជការដែលជាជនពិការ

-មន្ត្រីរាជការដែលមានកូនអាយុក្រោម១(មួយ)ឆ្នាំ

-មន្ត្រីរាជការដែលមានជំងឺរាំរ៉ៃមានការបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច និងមានអាយុចាប់ពី ៥០(ហាសិប)ឆ្នាំឡើងទៅ

-មន្ត្រីរាជការដែលទទួលការបណ្តុះបណ្តាលបន្ថែមក្រៅម៉ោងធ្វើការ។

**ប្រការ៣.-**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.-**

លោកជំទាវ ឯកឧត្តមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅថ្នាក់ជាតិទាំងអស់ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦*

**រដ្ឋមន្ត្រី**

**ប៉ិច កន្ធាងាវី**

*កន្លែងទទួល*

*-ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"*
*-ក្រសួងមុខងារសាធារណៈ*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-អង្គភាពប្រឆាំងអំពើពុករលួយ*
*"ដើម្បីមុខការ"*
*-គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ*
*-គ្រប់សាលារាជធានី ខេត្ត*
*-គ្រប់មន្ទីរកិច្ចការនារីរាជធានី ខេត្ត*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ៤ "ដើម្បីអនុវត្ត"*
*-រាជកិច្ច*
*-ឯកសារ "កាលប្បវត្តិ"*